

# ជំនឿចំពោះព្រះពុទ្ធសាសនា

សេរីការ : មហាវិថីគ្មានទ្វារ វាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន

## អត្ថបទរបស់ សម្តេចព្រះពោធិវង្ស ហួត តាត

ប្រជាពលរដ្ឋខ្មែរ ក្នុងប្រទេសកម្ពុជា មានចំនួន ៩៥ភាគរយ ដែលមាន ជំនឿជឿជាក់ ចំពោះព្រះពុទ្ធសាសនា ហើយនាំគ្នាគោរពប្រត្តិបត្តិកាន់តាមឱវាទ ឬ ពាក្យប្រដៅ នៃព្រះពុទ្ធជាម្ចាស់តាំងពីច្រើនសតវត្សរ៍មកហើយ។ ប្រជាពលរដ្ឋខ្មែរដែលមានជំនឿ ចំពោះព្រះពុទ្ធសាសនា តើមានជំនឿយ៉ាងដូចម្តេចទៅ។ ប្រជាពលរដ្ឋខ្មែរ ដែលមានជំនឿ ចំពោះព្រះពុទ្ធសាសនានោះ បើពោលដោយសង្ខេប គឺមានជំនឿថា ព្រះពុទ្ធសាសនាជាសាសនាប្រកបដោយហេតុផល ជាសាសនាប្រកាស នូវសេចក្តីពិត ជាសាសនាប្រាប់ឲលះបង់សេចក្តីអាក្រក់ ឲធ្វើសេចក្តីល្អ ជាសាសនាដឹកនាំសត្តនិករ ឲងាកចេញពីផ្លូវខុស ឲដើរទៅរកតាមផ្លូវត្រូវ ជាសាសនាជួយសត្វលោក ឲស្គាល់មធ្យោបាយដោះខ្លួន ឲរួចផុតពីទុក្ខ ឲបានសម្រេច ដល់នូវសេចក្តីសុខក្សេមក្សាន្ត។ នេះជាជំនឿយ៉ាងសង្ខេបនសប្រជាពលរដ្ឋខ្មែរ។

ដោយអាស្រ័យ ជំនឿយ៉ាងមាំមួន ចំពោះព្រះពុទ្ធសាសនាដូចខាងលើនេះហើយ ទើបប្រជារាស្ត្រខ្មែរ ខំប្រឹងប្រតិបត្តិធ្វើតាមព្រះពុទ្ធឱវាត គឺខំលះបង់អំពើអាក្រក់ (បាប) ហើយខំប្រឹងធ្វើអំពើល្អ (បុណ្យ) ច្រើនបែបច្រើនយ៉ាងដូចតទៅនេះ។

# ជំនឿចំពោះព្រះពុទ្ធសាសនា

## ១. ធ្វើទាន

គឺលះសេចក្ដីកំណាញ់ វិច្ឆាកទ្រព្យរបស់ខ្លួន ចែកចាយដល់អ្នកដទៃ ដោយសេចក្ដីសង្គ្រោះ ឲគេបានសុខស្រួលផង ឬ បរិច្ចាកទ្រព្យបំពេញការកុសលផ្សេងៗ គឺ៖

ក. ប្រគេនចីវរប្បច្ច័យ គឺស្បង់ចីពរ ដល់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឬ ចែកសំពត់អាវគ្រឿងស្លៀកពាក់ដល់ជនដែលទាល់ក្រខ្វទៅ មិនចំពោះមនុស្សណានីមួយ។

ខ. ប្រគេនបិណ្ឌបាតប្បច្ច័យ គឺភោជនាហារ ដល់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឬ ឲភោជនាហារដល់សាធារណជនដែលក្រីក្រ។

គ. ប្រគេនសេនាសន្តប្បច្ច័យ គឺគ្រឿងដេកអង្គុយ មានកន្ទេលខ្នើយជាដើម ឬ កសាងវត្តអារាមក្នុងពុទ្ធសាសនា មានវិហារ, សាលា, កុដិជាដើម។ ឧទ្ទិសចំពោះព្រះសង្ឃក្នុងពុទ្ធសាសនា ឬ ក៏ឲគ្រឿងដេកអង្គុយ មានកន្ទេលខ្នើយជាដើមដល់សាធារណជន ដែលទីទល់ក្រលំបាក ឬ មួយក៏កសាងសាលារៀន, សាលាសំណាក់, ស្ពាន, ជិកអណ្ដូង, ជិកស្រះជាដើម ទុកជាកុសលសាធារណៈ ដើម្បីឲសាធារណជនបានទទួលប្រើប្រាស់រាល់គ្នា។

ឃ. ប្រគេនគិលានភេសជ្ជប្បច្ច័យ គឺឱសថដល់ព្រះសង្ឃក្នុងពុទ្ធសាសនា ដែលមានជម្ងឺ ឬ ក៏ចែកឱសថដល់ជនសាធារណៈដែលមានជម្ងឺឈឺចាប់។

ការធ្វើទាន ដោយបច្ច័យទាំង៤ខាងលើនេះ អ្នកកាន់ព្រះពុទ្ធសាសនាជាតិខ្មែរ រមែងតែងបានធ្វើជាញឹកញាប់រឿយៗ ដោយមានជំនឿជឿព្រះពុទ្ធភាសិតថា អ្នកមានចិត្តល្អ តែងតែបានសុខ, អ្នកសង្គ្រោះគេ តែងទទួលសេចក្តីសង្គ្រោះវិញ, អ្នកបូជាគេ តែងបានការបូជាវិញ, អ្នកដែលប្រាថ្នាចង់បានសេចក្តីសុខដល់ខ្លួន ហើយធ្វើឲកើតទុក្ខ ដល់អ្នកដទៃនោះនឹងមិនសម្រេចដូចបំណងឡើយ នឹងត្រឡប់បានសេចក្តីទុក្ខទៅវិញ លុះតែចែកសេចក្តីសុខដល់អ្នដទៃ ទើបសេចក្តីនោះនឹងត្រូវត្រឡប់បានមកវិញ។

## ២. រក្សាសីល

គឺតាំងចិត្តវៀរលែង ប្រព្រឹត្តធ្វើអំពើអាក្រក់៥យ៉ាង ហៅថាសីល ៥ (និច្ចសីល) គឺ៖

ក. មិនសម្លាប់សត្វ ទោះធំក្តីតូចក្តី,

ខ. មិនលួចទ្រព្យសម្បត្តិអ្នកដទៃ ទោះតិចក្តីច្រើនក្តី,

គ. មិនប្រព្រឹត្ត បំពានបំពារក្នុងផ្លូវកាម លើកូនប្រពន្ធអ្នកដទៃ,

ឃ. មិននិយាយកុហក,

ង. មិនផឹកទឹកស្រវឹង ដែលធ្វើឲខ្លួនងេងងោងភ័ន្តគំនិតពុទ្ធសាសនាជាតិខ្មែរ ដែលបានរក្សាសីល៥ ខាងលើនេះខ្ជាប់ខ្ជួន ហើយ ខ្លះក៏បានរក្សារហូតដល់សីល១០ (អភិរេកសីល) ក៏មាន។

ពុទ្ធសាសនិកជាតិខ្មែរ ដែលនាំគ្នារក្សាសីល៥ ជាដើមដូចខាងលើនេះ ជានិច្ចនិរន្តរ៍ ដោយមានជំនឿជឿពាក្យប្រៀនប្រដៅព្រះពុទ្ធជាម្ចាស់ថា អ្នកដែលត្រូវការចង់បានសេចក្ដីសុខ ត្រូវមានមេត្តាធម៌ គឺសេចក្ដីអាណិត ឬ រាប់អានចំពោះខ្លួនឯងផង ចំពោះមនុស្សសត្វទទៃទៀតផង មិនត្រូវបៀតបៀន ឬមើលងាយអ្នកដទៃណាមួយឡើយ ព្រោះមនុស្សសត្វទាំងអស់ក្នុងលោក ត្រូវការចង់រស់នៅដូចគ្នា, ចង់ឲមានទ្រព្យសម្បត្តិដូចគ្នា, ចង់ឲគ្រួសាររបស់ខ្លួន មានតម្លៃថ្លៃថ្នូរដូចគ្នា, ចង់ឲបានរួចផុត ពីការកុហកបោក បញ្ឆោតពីសំណាក់អ្នកដទៃដូចគ្នា, ចង់ឲមានប្រាជ្ញាភ្លឺស្វាងដូចគ្នា។

## ៣. ចំរើនភាវនា

គឺការទូន្មានចិត្ត, ការហាត់ចិត្តកុំឲចិត្តជាប់នៅក្នុងអារម្មណ៍អាក្រក់ ដែលសម្រាប់ធ្វើចិត្តឲសៅហ្មង, ឲបានចិត្តនៅក្នុងអារម្មណ៍ដ៏ល្អ ដែលសម្រាប់ធ្វើចិត្តឲបានស្អាតល្អ។ ពុទ្ធសាសនិកជាតិខ្មែរ ពេញចិត្តនឹងការចំរើនភាវនានេះណាស់ ដោយមានជំនឿពាក្យប្រដៅ របស់ព្រះពុទ្ធជាម្ចាស់ថា អំពើអាក្រក់គ្រប់យ៉ាង កើតឡើងអំពីចិត្តអាក្រក់, អំពើល្អគ្រប់យ៉ាង កើតឡើងអំពីចិត្តល្អ។ ចិត្តអាក្រក់ គឺចិត្ត ដែលសៅហ្មងដោយលោភៈ, ទោ

ស:, មោហ:។ ចិត្តល្អ គឺចិត្តដែលមិនសៅហ្មង ដោយលោភ:, ទោស:, មោហ:។ ចិត្តអាក្រក់តែងដឹកនាំមនុស្ស ឲធ្វើអំពើអាក្រក់ មានការកាប់សម្លាប់គេ, លួចទ្រព្យសម្បត្តិគេ ឬ នាំឲមានការឈ្លោះប្រកែកជាដើម។ ចិត្តល្អតែងនាំមនុស្ស ឲធ្វើអំពើល្អ មានការជួយសង្គ្រោះអ្នកដទៃជាដើម។ មនុស្សចិត្តអាក្រក់ បើនៅកន្លែងណា កន្លែងនោះមិនបានសេចក្តីសុខស្រួលទេ, រីឯមនុស្សចិត្តល្អ បើនៅទីណា ទីនោះសុខសប្បាយឥតមានរឿងឈ្លោះប្រកែកអ្វីឡើយ។

ប្រជារាស្ត្រខ្មែរ ដែលមានជំនឿ ចំពោះព្រះពុទ្ធសាសនា មិនមែនគ្រាន់តែធ្វើទានរក្សាសីល និង ភាវនា ដូចខាងលើនេះហើយ ធ្វើព្រងើយកន្តើយឡើយ, បានទាំងខំប្រឹង បំពេញកិច្ចការផ្សេងៗ ដែលមាន ប្រយោជន៍ដល់ប្រទេសជាតិ ជាពិសេសដល់ជីវភាព រៀងៗខ្លួនផងទៀត ព្រោះប្រជារាស្ត្រខ្មែរ បានទទួលការសិក្សា និង ការអប់រំ តាមកន្លងព្រះពុទ្ធសាសនាជាយូរអង្វែងណាស់ហើយ តាំងពីបុព្វបុរស របស់ខ្លួនជាប់តមកដោយមាន គម្ពីរសៀវភៅតម្រាប់តម្រាល សម្រាប់ប្រដៅប្រជាពលរដ្ឋច្រើន តែជាប់ទាក់ទងនឹង ព្រះពុទ្ធសាសនាទាំងអស់ដូចមានស្រង់យកមកចារឹកទុកជាភ័ស្តុតាងខ្លះដូចតទៅនេះ :

## ១. សង្គមមនុស្ស

ដែលមានគ្នា តាំងពីពីរនាក់ឡើងទៅ បើមានការព្រមព្រៀងគ្នា ទើបមានសេចក្តីសុខ។

**២. កុំបង្កឲមានរឿងវិវាទ**

គឺ ការឈ្លោះប្រកែកគ្នានឹងគ្នាឡើយ ព្រោះការឈ្លោះប្រកែកគ្នាជាហេតុ នាំឲដល់សេចក្តីវិនាស។

**៣. ត្រូវឲមានខន្តីធម៌**

គឺ ការអត់ឱន ឬ ការទប់ចិត្តកុំខឹងច្រឡោតផ្តេសផ្តាស់ ព្រោះកំហឹងនាំឲយល់ខុស។

**៤. មិនត្រូវបៀតបៀនអ្នកណាមួយ**

ឲគេបានទុក្ខទោស ព្រោះក្នុងលោកនេះ ចង់បានតែសុខចំរើនដូចគ្នា។

**៥. ត្រូវខំប្រឹងសិក្សា ឬ ខំប្រឹងធ្វើការងារ ដោយយកចិត្តទុកដាក់**

ការខំប្រឹងនោះ អាចនាំឲសម្រេចប្រយោជន៍ ដែលខ្លួនត្រូវការ។

**៦. មិនត្រូវខ្ជិលច្រអូសឡើយ**

ព្រោះកំជិលនោះ អាចនាំខ្លួនឲទៅជួបនឹងការហិនហោច។

**៧. ត្រូវឲមានកតញ្ញូតានិងកតវេទិតា**

គឺដឹងគុណនិងតបគុណ ចំពោះអ្នកដែលមានគុណូបការៈលើខ្លួន ព្រោះការដឹងគុណជាធម៌របស់មនុស្ស។

## ៨. មិនត្រូវប្រមាថមើលងាយ

អ្នកឯទៀត ដែលទន់ទាបជាងខ្លួន ដែលក្រីក្រជាងខ្លួន និងល្ងង់ជាងខ្លួនឡើយ ព្រោះការមើលងាយគេ នឹងផលអាក្រក់ដល់ខ្លួន។

## ៩. កើតបានជាមនុស្សហើយ

គួររក្សាឋានៈ របស់មនុស្សឲគង់នៅ, កុំឲឋានៈនោះធ្លាក់ទៅនៅស្មើគ្នានិងឋានៈរបស់តិរច្ឆាន។

## ១០. ជីវិតមនុស្សជាអសារៈ

ឥតមានខ្លឹមសារទេ ប៉ុន្តែអ្នកមានគំនិតល្អ អាចធ្វើឲជីវិតមានសារៈ គឺខ្លឹមសារបាន។